00375592

**Declassified to Public**
**12 April 2013**

D130/9/7

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-២៦) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ |
| ភាគីអ្នកដាក់ | : | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | : | ភាសាអង់គ្លេស |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 09 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ពាក្យសុំពន្យារពេលជាបន្ទាន់ របស់សហព្រះរាជអាជ្ញា ក្នុងការដាក់ចម្លើយតបរួមទៅនឹង បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម

**អ្នកដាក់ឯកសារ:**

**ការិយាល័យសហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក William SMITH
លោក យ៉េត ចរិយា
លោក សេង បុនឃាង
លោក Vincent de WILDE d'ESTMAEL

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម ហួត វុទ្ធី
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS

**សហមេធាវីរបស់ អៀង ធីរិទ្ធ:**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS

**សហមេធាវីរបស់ ខៀវ សំផន:**
លោក សា សុវ៉ាន
លោក Jacques VERGÈS

## សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣៩.៤.ក នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា ស្នើសុំពន្យារពេលជាបន្ទាន់ក្នុងការដាក់ចម្លើយតបរួមរបស់ពួកខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍រៀងៗខ្លួនរបស់ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ("ដីកាសម្រេច") ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩[1] ។ សហព្រះរាជអាជ្ញា ស្នើសុំពន្យារពេលចំនួនដប់បួន (១៤) ថ្ងៃ ដូចគ្នានឹងរយៈពេលដែលអង្គបុរេជំនុំជម្រះបានផ្តល់ឲ្យសហមេធាវីរបស់ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩[2] ។ សហព្រះរាជអាជ្ញា ក៏សូមជម្រាបដល់អង្គបុរេជំនុំជម្រះ ផងដែរអំពីបំណងរបស់ខ្លួនក្នុងការដាក់ចម្លើយតបរួមមួយទៅនឹងបណ្តឹងឧទ្ធរណ៍ដែលបានដាក់រៀងៗខ្លួនដោយឈ្មោះ អៀង ធីរិទ្ធ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩[3] និង ខៀវ សំផន នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ (បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសត្រូវបានជូនដំណឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩)[4] ។

## សេចក្តីសង្ខេបអង្គហេតុដែលពាក់ព័ន្ធ

២. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីរបស់ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ បានដាក់សេចក្តីជូនដំណឹងមួយ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច (D130/9) ។ នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តី បានដាក់សំណើសុំពន្យារពេល ដោយស្វែងរកឲ្យ

[1] ដីកាសម្រេចរបស់ សចស លើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី២៨ កក្កដា ២០០៩, D130/8, ERN 00355926-33 (ភាសាអង់គ្លេស) ។

[2] សេចក្តីសម្រេចរបស់ អបជ លើពាក្យសុំរបស់មេធាវីការពារក្តី ស្នើសុំពន្យារពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី១៨ សីហា ២០០៩, D130/9/2, ERN 00361767-69 (ភាសាអង់គ្លេស) ។ កត់សម្គាល់ថា តាមសេចក្តីសម្រេចមួយ ចុះថ្ងៃទី០៤ កញ្ញា ២០០៩ (D130/9/5), អង្គបុរេជំនុំជម្រះសម្រេចថា ពាក្យសុំពន្យារពេលមួយពីលើកមុនរបស់សហព្រះរាជអាជ្ញា គឺបានធ្វើឡើងមុនកាល ហើយសម្រេចថា មិនអាចទទួលយកបានទេ។

[3] បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី១០ កញ្ញា ២០០៩, ), D130/9/6, ERN 00374841-72 (ភាសាអង់គ្លេស), ERN 00374873-4917 (ភាសាខ្មែរ) ។

[4] បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី២៧ សីហា ២០០៩ (អបជ-២៧), D130/10/1, ERN 00374825-28 (ភាសាអង់គ្លេស) និង ERN 00367321-24 (ភាសាបារាំង) ។

មានការពន្យារពេលចំនួនដប់បួន (១៤) ថ្ងៃបន្ថែមទៅលើពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន (D130/9/1) ។ នៅក្នុងសំណើនោះ ត្រង់កថាខ័ណ្ឌទី ៥ សហមេធាវីការពារក្តី បានថ្លែងថាប្រសិនបើការពន្យារនេះត្រូវបានអនុញ្ញាត "សហមេធាវីការពារក្តី នឹងមិនជំទាស់ទៅនឹងសំណើស្រដៀងគ្នានេះ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ឬដោយភាគីដទៃទៀតទេក្នុងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ"។ សហមេធាវីការពារក្តី បានបញ្ជាក់អំពីការមិនជំទាស់របស់ពួកខ្លួននៅក្នុង "ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងពាក្យសុំពន្យារពេល របស់សហព្រះរាជអាជ្ញា" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ (D130/9/4) ។

៣. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះ បានអនុញ្ញាតលើសំណើសុំពន្យារពេលរបស់សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ចំនួនដប់បួន(១៤)ថ្ងៃ ដោយបានបង្គាប់ថា បណ្តឹងឧទ្ធរណ៍របស់ពួកគេត្រូវ ដាក់នៅថ្ងៃព្រហស្បត្តិ៍ ទី១០ ខែកញ្ញា ឆ្នាំ២០០៩ នៅវេលាម៉ោង ១២:០០ ថ្ងៃត្រង់ (D130/9/2) ។ បណ្តឹងឧទ្ធរណ៍នោះ ត្រូវបានដាក់នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ហើយត្រូវបានជូនដំណឹងដល់សហព្រះរាជអាជ្ញា ជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ (D130/9/6) ។ ដោយហេតុនេះ កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញា គឺនៅថ្ងៃសុក្រ ទី២៥ ខែកញ្ញា ឆ្នាំ២០០៩[5] ។

៤. ទោះបីពួកគេមិនបានជូនដំណឹងថានឹងមានដាក់បណ្តឹងខ្ធរណ៍ណាមួយ ក្នុងរយៈពេលដប់ (១០) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែល សចស ចេញដីកាជូនដំណឹងក៏ដោយ ក៏មេធាវីការពារក្តីរបស់ ខៀវ សំផន បានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាដដែលនោះនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ផងដែរ ។ បណ្តឹងឧទ្ធរណ៍ដែលត្រូវបកប្រែឲ្យទៅជាភាសាអង់គ្លេសនោះ ត្រូវបានជូនដំណឹងដល់សហព្រះរាជអាជ្ញា នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩។ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន មានយោងជាមុនយ៉ាងសំខាន់ទៅលើតែសំអាងនានា ដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍ខាងមុខនេះរបស់ អៀង ធីរិទ្ធ ។ សហព្រះរាជអាជ្ញា ពិចារណាថាការឆ្លើយតបទៅនឹងសំអាងទាំងឡាយរបស់ ខៀវ សំផន ស្របពេលនឹងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ នៅក្នុងចម្លើយ

---

[5] មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តក្នុងការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក បានអនុញ្ញាតឲ្យដាក់ឯកសារ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃប្រតិទិន ជាការឆ្លើយតបទៅនឹងសារណាណាមួយ ។ មាត្រា ៨.៥ចែងថាពេលវេលាកំណត់ ត្រូវចាប់ផ្តើមរាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងនៃសារណានោះ ។

តបរួមមួយជាមួយគ្នាតែម្តង គឺបានគាំទ្រដល់បញ្ហាថវិការបស់អង្គជំនុំជម្រះ និងការគ្រប់គ្រងដ៏ល្អលើវិស័យយុត្តិធម៌ ។

៥. នៅក្នុងអំឡុងពេលដែលការិយាល័យសហព្រះរាជអាជ្ញា នឹងត្រូវបានតម្រូវឲ្យធ្វើសេចក្តីព្រាង និងធ្វើការបកប្រែនូវចម្លើយតបរួមរបស់ខ្លួននោះ មន្ត្រីច្បាប់សំខាន់ៗចំនួនពីរ (២) រូបរបស់សហព្រះរាជអាជ្ញា ដែលបានធ្វើការលើញត្តិនានាដែលពាក់ព័ន្ធនឹងបញ្ហានៃការធ្វើទារុណកម្មនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ត្រូវបានចាត់តាមកាលវិភាគឲ្យទៅធ្វើការងារលើសំណុំរឿងលេខ ០០១ នៅក្នុងសវនាការរបស់ **ឌុច** (សវនាការនានានៅថ្ងៃខាងមុខនេះ និងការត្រៀមរៀបចំធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការចោទប្រកាន់)។ បន្ថែមលើនេះ កាលបរិច្ឆេទនានា គឺនៅថ្ងៃសុក្រ ទី១៨ ខែកញ្ញា ឆ្នាំ២០០៩ និងនៅថ្ងៃច័ន្ទ ទី២១ ខែកញ្ញា ឆ្នាំ២០០៩ គឺជាថ្ងៃឈប់សម្រាក ជាផ្លូវការនៅអង្គជំនុំជម្រះនេះ សម្រាប់ទាំងបុគ្គលិកជាតិ និងទាំងបុគ្គលិក អសប (បុណ្យភ្ជុំបិណ្ឌ) ហើយនិងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩ គឺជាថ្ងៃប្រកាសរដ្ឋធម្មនុញ្ញ ដែលជាថ្ងៃឈប់សម្រាកសម្រាប់បុគ្គលិកជាតិ ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា ប្រមើលមើលឃើញថា ដោយមកពីមានថ្ងៃឈប់សម្រាក និងមានកាតព្វកិច្ចផ្សេងៗដែលបុគ្គលិកផ្នែកច្បាប់ត្រូវបានចាត់ឲ្យធ្វើកិច្ចការនេះ នោះមុខជានឹងតម្រូវឲ្យមានពេលវេលាបន្ថែមនៅក្នុងការដាក់ជូននូវចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនេះជាមិនខាន ។

## សេចក្តីសំអាង

៦. បញ្ហាខាងអង្គច្បាប់ដែលទាក់ទងទៅនឹងភាពដែលអាចទទួលយកបាន និងការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរស-២១ ធ្វើជាភស្តុតាងគឺមានសារៈសំខាន់ដ៏ធំធេងណាស់ដល់ដំណើរការនៃនីតិវិធីនៅចំពោះមុខតុលាការនេះ ហើយដែលភាគីនានាគួរតែត្រូវបានផ្តល់នូវពេលវេលាឲ្យបានគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវឲ្យបានត្រឹមត្រូវ និងធ្វើសារណាលើបញ្ហាទាំងនេះ ។ ដោយសារតែមានប្រយោជន៍ដ៏ធំធេងនៃបណ្តឹងឧទ្ធរណ៍ទាំងនេះ និងម្យ៉ាងទៀតដោយសារតែសហព្រះរាជអាជ្ញា មិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការលើបញ្ហានេះ ចាប់ពីចន្លោះថ្ងៃទី១១ រហូតដល់ដាច់ខែកញ្ញា ឆ្នាំ២០០៩ នោះ សូមជូនជាយោបល់ថា ដើម្បីជាការសមស្រប សូមអង្គបុរេជំនុំជម្រះ អនុញ្ញាតឲ្យមានពេលវេលាបន្ថែមទៀតសម្រាប់ឲ្យសហព្រះរាជអាជ្ញា ដាក់ជូននូវសេចក្តីសន្និដ្ឋានឆ្លើយតបរួមរបស់ខ្លួននេះ ។

៧. សហព្រះរាជអាជ្ញា ស្នើសុំការពន្យារពេលមួយដែលដូចគ្នានឹងការពន្យារពេលដែលអង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យដល់សហមេធាវីការពារក្តីរបស់ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍របស់ពួកគេដែរ ។ សហព្រះរាជអាជ្ញា ស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ អនុញ្ញាតឱ្យពួកគេបានដាក់នូវចម្លើយតបរួមនោះនៅថ្ងៃច័ន្ទ ទី១២ ខែតុលា ឆ្នាំ២០០៩ ។ សហមេធាវីការពារក្តីរបស់ឈ្មោះ អៀង ធីរិទ្ធ បានថ្លែងចំនួនពីរដងថា ពួកគេមិនជំទាស់ទៅនឹងការអនុញ្ញាតឱ្យមានការពន្យារពេលបន្ថែមឱ្យដល់សហព្រះរាជអាជ្ញា នោះទេ[6] ។ ការពន្យារពេលនេះ នឹងមិនបណ្តាលឱ្យមានការខូចខាតដ៏សំខាន់ណាមួយដល់សិទ្ធិរបស់ជនត្រូវចោទនោះទេ ក៏ប៉ុន្តែបានបំរើដល់គោលដៅយុត្តិធម៌ថែមទៀតផង ។ សហព្រះរាជអាជ្ញា ស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ ធ្វើការសម្រេចលើពាក្យសុំនេះជាបន្ទាន់ ។

## សេចក្តីសន្និដ្ឋាន

៨. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ ធ្វើការសម្រេចលើពាក្យសុំនេះជាបន្ទាន់ ព្រមទាំងអនុញ្ញាតឱ្យ សហព្រះរាជអាជ្ញា ធ្វើការដាក់ចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍រៀងៗខ្លួនរបស់ឈ្មោះ អៀង ធីរិទ្ធ និង ខៀវ សំផន នៅថ្ងៃច័ន្ទ ទី១២ ខែតុលា ឆ្នាំ២០០៩ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | [signature and seal] |
| | **លោក** William SMITH<br>**សហព្រះរាជអាជ្ញាស្តីទី** | ភ្នំពេញ | |

[6] សំណើជាបន្ទាន់របស់មេធាវីការពារ ស្នើសុំពន្យារពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម", ចុះថ្ងៃទី៣១ កក្កដា ២០០៩, D130/9/1, ERN 00357072-73 (ភាសាអង់គ្លេស), កថាខណ្ឌទី ៥ ។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងពាក្យសុំពន្យារពេលដាក់សារណាតបរបស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី២៧ សីហា ២០០៩, D130/9/4, ERN 00369835-36 (ភាសាអង់គ្លេស) ។